ភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៣

**សារាចរណែនាំ លេខ : ១១ សរណន**

**រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា**

**សូមជំរាបមក**

ឯកឧត្តមរដ្ឋមន្ត្រី គ្រប់ក្រសួង – ស្ថាប័ន

លោក អភិបាល គ្រប់ ខេត្ត – ក្រុង

**កម្មវត្ថុ** : ស្ដីពីការប្រមូលឯកសារមកតំកល់ទុក

**យោង** : សេចក្ដីប្រកាសរបស់រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ។

ដោយយល់ឃើញថា : ឯកសារគ្រប់ប្រភេទរបស់ជាតិនីមួយៗ គឺជាទ្រព្យសម្បត្តិ និង ជាប្រវត្តិសាស្ត្រដ៏មាន តម្លៃខ្ពង់ខ្ពស់ ពុំអាចកាត់ថ្លៃបានឡើយ ។ ហើយបច្ចុប្បន្ននេះរដ្ឋាភិបាលរំលាយផ្ទេរ បង្កើតថ្មី ក្រសួងមួយចំនួន។

ដូច្នេះចំពោះមុខនេះការងារប្រមូលឯកសារសំណុំរឿងផ្សេងៗរបស់ជាតិយកមកតំកល់ទុកនៅឃ្លាំងឯកសារគឺ ជាការពិតជាចាំបាច់ និង ជាបន្ទាន់ ។ ពុំអាចពន្យារពេលទុកយូរតទៅទៀតបានឡើយ ។ ជាហេតុនាំអោយបាត់បង់អន្តរាយ ឯកសាររបស់ជាតិដ៏ធំធេង ។

ហេតុនេះរដ្ឋាភិបាលបណ្ដោះអាសន្នជាតិកម្ពុជា សូមអោយគ្រប់ក្រសួង – ស្ថាប័ន គ្រប់ខេត្ត – ក្រុង ទាំងអស់ណែនាំដល់មន្ត្រីទទួលខុសត្រូវទាំងអស់ហាមបំផ្លិចបំផ្លាញឯកសារទាំងអស់ជាដាច់ខាត ។ ប៉ុន្តែមុននឹងប្រគល់ ត្រូវធ្វើបញ្ជី ឬ តារាងសំណុំរឿង ឯកសារទាំងនោះអោយបានត្រឹមត្រូវ ។ ហើយជូនដំណឹង និង ភ្ជាប់តារាងសំណុំ រឿងឯកសារទាំងអស់នោះមក[illegible] ដើម្បីចុះពិនិត្យ និង ធ្វើកំណត់ហេតុប្រគល់ ទទួលយកមកតំកល់ ទុកនៅឃ្លាំងឯកសាររបស់ជាតិ ។

ចំពោះក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ហើយនិង ក្រសួងការបរទេស ត្រូវមាន ឃ្លាំង ឯកសារ ដោយឡែក នៃក្រសួងនីមួយៗ រួចប្រមូលឯកសារទាំងអស់របស់រដ្ឋការ ចំណុះយកមកតំកល់ ទុកហើយត្រូវ គ្រប់គ្រង អោយបានត្រឹមត្រូវតាមបច្ចេកទេសបណ្ណសារ ដើម្បីការពារកុំអោយបាត់បង់ឯកសារ ។

ចំពោះខេត្ត – ក្រុង ត្រូវមានឃ្លាំងមួយតាំងនៅសាលាខេត្ត ហើយក៏ត្រូវប្រមូលឯកសារគ្រប់អង្គភាព ចំណុះ យកមកតំកល់ទុក រួចត្រូវមានបញ្ជីស្ថិតិ ដើម្បីគ្រប់គ្រងតាមបច្ចេកទេសបណ្ណសារ ។ ឯមន្ទីរនគរបាល និង យោធា ត្រូវគ្រប់គ្រងឃ្លាំងឯកសារ ទាំងអស់ នៅ កន្លែងរៀងៗខ្លួនអោយបានល្អ ។

ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវណែនាំអោយនាយកដ្ឋានតំកល់ឯកសារជាតិ ចុះសហការអនុវត្តលក្ខណៈបច្ចេក ទេសមុនពេលប្រមូលទទួលយកតំកល់ទុកនៅឃ្លាំងរបស់ជាតិ តាមលំដាប់លំដោយ ។

បានទទួលសារាចរណែនាំនេះ សូមព្រះអង្គម្ចាស់ ឯកឧត្តមរដ្ឋមន្ត្រី គ្រប់ក្រសួង - ស្ថាប័ន អស់លោក អភិបាល គ្រប់ខេត្ត - ក្រុង ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.សហប្រធាន

រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

គាត ឈន់ អ៊ុង ផន

* * * *

ភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៣

**សារាចរ លេខ : ១២ សរ**

សហប្រធានរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

**សូមគោរពជូន និង ជំរាបមក**

- ព្រះអង្គម្ចាស់ ឯកឧត្តមរដ្ឋមន្ត្រីគ្រប់ក្រសួង
- អស់លោក អភិបាលខេត្ត ក្រុង ទូទាំងប្រទេស

**កម្មវត្ថុ** : អំពីការណែនាំបន្ថែមលើការប្រារព្ធពិធីគោរពទង់ជាតិ ។

**យោង** : សារាចរ ស្តីអំពីការប្រារព្ធពិធីគោរពទង់ជាតិ លេខ ០៧ សរ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៣ ។

- សារាចរណែនាំ ស្តីអំពីការណែនាំការប្រារព្ធពិធីគោរពទង់ជាតិលេខ ០១ សរណន ចុះ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣ ។

ដោយពិនិត្យឃើញថាមួយរយៈពេលកន្លងមកនេះ នៅតាមក្រសួង ស្ថាប័ន អង្គភាពមន្ទីរ ពេទ្យនិងសាលារៀនអនុវត្តបានល្អក្នុងការប្រារព្ធពិធីគោរពទង់ជាតិប៉ុន្តែនៅតាមដងផ្លូវទីប្រជុំជនសាធារណៈទីផ្សារលក់ដូរ